ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៧៧ / ១៥.គកជ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមការងារសហប្រតិបត្តិការអន្តរជាតិ

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ:០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការ បង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចរាជរដ្ឋាភិបាល លេខ១៤៥ សសរ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

**ប្រការ១.**

ត្រូវបានតែងតាំងសមាសភាពក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពដូចខាងក្រោម ៖

១. លោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី (ក.ក.ន) **ប្រធាន**

២. លោកជំទាវ **សាន្ត អរុណា** រដ្ឋលេខាធិការក្រសួងកិច្ចការនារី អនុប្រធានអចិន្ត្រៃយ៍

៣. ឯកឧត្តម **សៀង ឡាប្រេស្ស** ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន (SOMTC) អនុប្រធាន

៤. ឯកឧត្តម **គីម សន្តិភាព** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ អនុប្រធាន

៥. លោកជំទាវ **ចី សាមីន** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៦. លោកជំទាវ **រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ អនុប្រធាន

៧. លោកជំទាវ **ប៊ុន ពុទ្ធី** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក

៨. លោកជំទាវ អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក.ក.ន សមាជិក

៩. លោកជំទាវ **ហេង ស៊ីថុន** ទីប្រឹក្សា និងជាសមាជិកអចិន្ត្រៃយ៍ ឧមមីត សមាជិក

១០. លោកស្រី **ស៊ុន វណ្ណា** អគ្គនាយករង នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក.ក.ន សមាជិក

១១. លោកស្រី **ដើត ហាន** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិក.ក.ន សមាជិក

១២. លោកជំទាវ **ជា ផល្លីន** ទីប្រឹក្សា ក្រសួងព័ត៌មាន សមាជិក

១៣. លោក **វ៉េង ហៀង** ប្រធាននាយកដ្ឋានការងារកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៤. លោកស្រី **អ៊ុំ វណ្ណាឫទ្ធី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម ជនរងគ្រោះក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា សមាជិក

១៥. លោកស្រី **ហ៊ាន ម៉ូលីណោ** ប្រធាននាយកដ្ឋាន អាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៦. លោកស្រីវេជ្ជ **ប្រាក់ សោភ័ណនារី** អនុប្រធានមជ្ឈមណ្ឌល គាំពារមាតា និងទារក ក្រសួងសុខាភិបាល សមាជិក

១៧. លោកស្រី **ម៉ុច វលក្ខណ៍** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន ក្រសួងទេសចរណ៍ សមាជិក

១៨. ឧត្តមសេនីយ៍ត្រី **ស ម៉ូលីនីន** អនុប្រធាននាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារ អនីតិជន អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

១៩.វរសេនីយ៍ឯក **សួន សុជាតិ** អនុប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

២០.កញ្ញាវរសេនីយ៍ត្រី **កេតរៈ ស្រីវល័ក្ខណ៍** អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋាន អត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ សមាជិក

២១. វរសេនីយ៍ទោ **អៀម វាសនា** នាយការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២២. ឧត្តមសេនីយ៍ទោ **អន សឹង** នាយករងទីចាត់ការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ សមាជិក

២៣. លោកជំទាវ **មៀច សុធារី** អគ្គលេខាធិការ សមាគមនារីកម្ពុជាដើម្បីសន្តិភាព និង អភិវឌ្ឍន៍ (CWPD) សមាជិក

| | | | |
|---|---|---|---|
| ២៤. លោក | **លឹម ទិត្យ** | តំណាងអង្គការសហប្រជាជាតិដើម្បីសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស កម្ពុជា (UN-ACT) | សមាជិក |
| ២៥. លោកស្រី | **Lisa J.Choeng** | នាយកប្រចាំប្រទេសអង្គការ Ratanak International | សមាជិក |
| ២៦. លោកស្រី | **ម៉ែន ចិន្តាមុនី** | ប្រធានគម្រោងថ្នាក់ជាតិផ្នែកគោលនយោបាយ អង្គការទស្សនៈពិភពលោក (World Vision) | សមាជិក |
| ២៧. លោកស្រី | **ម៉ម សុមាលី** | ប្រធានអង្គការអាហ្វេស៊ីប (AFESHIP) | សមាជិក |
| ២៨. លោកស្រី | **លី ស៊ុនលីណា** | ប្រធានសម្របសម្រួលគម្រោងថ្នាក់ជាតិ (AAPTIP) | សមាជិក |
| ២៩. តំណាង | | អង្គការវិនរ៉ក់អន្តរជាតិ ( Winrock International) | សមាជិក |
| ៣០. តំណាង | | អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) | សមាជិក |
| ៣១. តំណាង | | អង្គការឃែរកម្ពុជា (CARE Cambodia) | សមាជិក |

**ប្រការ២.**

ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រការ៧ នៃសេចក្តីសម្រេចគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពី ការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព ។ ប្រធានក្រុមការងារ អាចចាត់តាំងមន្ត្រី ជាជំនួយតាមការចាំបាច់ ។

អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិដែលមានគោលដៅស្របទៅនឹងភារកិច្ចដែលកំណត់ដោយសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ខាងលើនេះ អាចស្នើសុំចូលជាសមាជិកក្រុមការងារ មកប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងចាត់តំណាងផ្លូវការមកចូលរួម តាមការអញ្ជើញរបស់ប្រធានក្រុម ។

**ប្រការ៣.**

ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អង្គការដៃគូ ពាក់ព័ន្ធជាតិ និងអន្តរជាតិ និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ
- ក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ
- សាមីខ្លួនដូចប្រការ១
- ឯកសារ កាលប្បវត្តិ